# ប្រវត្តិនៃពិធីបុណ្យកឋិនទាន

តើអ្វីទៅដែលហៅថាកឋិន ?

កឋិននេះកើតឡើងដោយសារព្រះសម្មាសម្ពុទ្ធបរមគ្រូជាអម្ចាស់នៃយើងគ្រប់ព្រះអង្គទ្រង់បញ្ញត្តឡើងក្នុងមជ្ឈិមពោធិកាល ព្រោះហេតុភិក្ខុ ៣០រូបនៅទីក្រុងបាឋា ចម្រើនសមថវិបស្សនា លុះជិតដល់ពេលរដូវវស្សា ភិក្ខុទាំង ៣០រូបនោះមានបំណងទៅថ្វាយបង្គំព្រះពុទ្ធ ព្រះអង្គគង់នៅវត្តជេតពន លុះនិមន្តដើរទៅមិនទាន់ដល់វត្តជេតពន ទើបនឹងដល់ទីក្រុងសាកេត ក៏ដល់ថ្ងៃចូលវស្សា ទើបភិក្ខុទាំងនោះកំណត់ចូលវស្សានៅទីនោះនៅចម្ងាយផ្លូវតែ ៦ យោជន៏ទៀតដល់វត្តជេតពន។ លុះពេលចេញវស្សា ភិក្ខុទាំងនោះក៏នាំគ្នាចេញដំណើរពីទីក្រុងសាកេតឆ្ពោះទៅកាន់វត្តជេតពន ដើម្បីថ្វាយបង្គំព្រះសាស្ដា។

ពេលដែលនិមន្តចេញដំណើរទៅ ក្នុងពេលចេញវស្សានោះ នៅមានទឹកភ្លៀងរលឹម ប៉ប្រិចប៉ប្រាច់ ដីបែកភក់ ភិក្ខុទាំងនោះនិមន្តរអិលដួល ប្រឡាក់ភក់ស្បង់ចីពរ សង្ឃាដី សំពីងសំពោង លុះនិមន្តដល់វត្តជេតពន ក៏ចូលទៅថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ហើយគង់នៅដោយស្ងប់ស្ងៀម ទើបព្រះសាស្ដាចារ្យទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយរស់នៅដោយមានសាមគ្គីធមិរវាងគ្នាបានល្អដែរឬយ៉ាងណា? ហើយអាហារបិណ្ឌបាត្រអាចញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅបានដោយស្រួលដែរឬទេ ?

ភិក្ខុទាំងឡាយ ឆ្លើយថ្វាយព្រះអង្គថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងអស់គ្នានេះមានធមិសាមគ្គីចំពោះគ្នាទៅវិញទៅមកបានល្អ ឥតមានភិក្ខុអង្គណាមួយអរិចិត្តចំពោះគ្នានិងគ្នាទេ ព្រោះខ្ញុំព្រះអង្គទាំងអស់គ្នានេះឧបសម្បទា ដើម្បីលះបង់ចោលនូវអកុសលធមិមាន: លោភៈ ទោសៈ មោហៈ និងសំយោជនធមិ ដែលជាធមិចងក្រៀកសត្វទុកមិនឱ្យសត្វបានលះនូវអរិយមគ្គ អរិយផលបាន។ លោភៈ ចិត្តជាប់ជំពាក់ក្នុងបច្ច័យបួន មិនសន្ដោសទៅតាមអរិយវង្ស ទោសៈ ចិត្តខឹងប្រទូសចំពោះសត្វនិងសង្ខារ គឺមិនបានពិចារណារកខុសត្រូវឡើយ ខឹងប្រទូសវ៉ាយឥតឈប់ឈរចំពោះរបស់មានវិញ្ញាណ និងរបស់ឥតវិញ្ញាណ មោហៈ វង្វេងវង្វាន់ ភ័ន្តច្រឡំ មិនយល់ការពិត ខុសធ្វើជាត្រូវត្រូវធ្វើជាខុស អាក្រក់ធ្វើជាល្អៗធ្វើជាអាក្រក់ សុចរិតយល់ជាទុច្ចរិត ខ្មៅទៅជាស សទៅជាខ្មៅ។ ខ្ញុំព្រះអង្គមិនបានវិវាទទាស់ទែងគ្នាទេ ប៉ុន្តែខ្ញុំព្រះអង្គមកតាមផ្លូវមានការលំបាកយ៉ាងច្រើន ព្រោះដីភក់រអិលប៉ប្រិចប៉ប្រាច់ដួលក្នុងភក់ស្រកេកស្រកាក។

ទើបព្រះអង្គសម្ដែងធម្មិកថាពន្យល់ដល់ភិក្ខុទាំងឡាយអំពីសង្សារវដ្ដ ស្លាប់កើតៗស្លាប់ អន្ទោលពីមនុស្សទៅតិរច្ឆាន

មាននរក ប្រេត អសុរកាយជាដើម ។ លុះព្រះអង្គសម្តែងធម្មិកថាចប់ ភិក្ខុទាំង ៣០អង្គបានសម្រេចអរហត្តគ្រប់អង្គទាំងអស់ ។ ពេលភិក្ខុទាំងនោះថ្វាយបង្គំលាព្រះអង្គចេញផុតពីព្រះអង្គ ក៏និមន្តដោយឈានគ្រប់អង្គ ហោះហើរ ដើរតាមអាកាស ពេលនោះព្រះពុទ្ធទតមើលពីក្រោយឃើញសង្ឃាដី ឃើញបាត្រ រយីងរយោង សំពីងសំពោង ទើបព្រះអង្គទ្រង់មានព្រះវិតក្កថា ឱហ្ន៎! ប្រសិនបើតថាគតបានអនុញ្ញាតដល់ភិក្ខុទាំងឡាយឱ្យមានចូលវស្សាប្រាកដជាភិក្ខុទាំងឡាយមិនពិបាកយកសង្ឃាដីសំពីងសំពោងតាមខ្លួនទេ ។ ព្រះពុទ្ធគ្រប់ព្រះអង្គពីអតីតកាលក៏ទ្រង់បញ្ញត្តឱ្យមានកឋិនទានដល់ភិក្ខុសង្ឃដែរ ។ លុះព្រះអង្គទ្រង់ព្រះចិន្តាដូច្នេះហើយ ទើបប្រជុំភិក្ខុទាំងអស់ក្នុងពុទ្ធសាសនមណ្ឌលរបស់ព្រះអង្គ ទ្រង់មានព្រះពុទ្ធដីកាថា *អនុជានាមិ ភិក្ខវេ វស្សំ វុត្ថានំ ភិក្ខូនំ កឋិនំ អត្ថរិតុំ អត្ថតកឋិនានំ វោ ភិក្ខវេ បញ្ច កប្បិស្សន្តិ* ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុទាំងឡាយ ដែលនៅចាំវស្សារួចហើយទទួលក្រាលកឋិន ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥ប្រការ និងសម្រេចដល់ភិក្ខុទាំងឡាយ ដែលបានក្រាលកឋិនរួចហើយ ។

សេចក្តីបរិយាយខាងលើនេះជាបុព្វហេតុនៃកឋិន

កឋិនៈ៧ ស័ព្ទនេះ បានសេចក្តីថា ការប្រជុំរួបរួម ឬការប្រមូលផ្តុំនូវរូបធម៌ និងនាមធម៌ ឈ្មោះថា កឋិន ។ ដែលហៅថារូបធម៌ គឺរបស់ដែលមានរូបមើលឃើញដោយមំសចក្ខុធម្មតាបាន ដូចជា បរិក្ខារវត្ថុ មានៈ ស្បង់ ចីពរ សង្ឃាដី មុង កន្ទេល ខ្នើយ ។ល ។ ទាំងអស់នេះហៅថា រូបធម៌ ។ ឯនាមធម៌នោះ គឺរបស់ដែលមើលមិនឃើញដោយភ្នែកធម្មតា ដូចជាសេចក្តីសុខ ដែលកើតមានដល់ខ្លួន និងអានិសង្ស ៥ ដែលត្រូវបានដល់ភិក្ខុអ្នកទទួលមានសេរីភាពក្នុងខ្លួនចាប់តាំងពីបានក្រាលអនុមោទនាកឋិនពេលណាមក បដិគ្គាហកៈតែងបាននូវអានិសង្ស ៥យ៉ាងគឺ: ១.អនាមន្តចារោ ត្រាច់ទៅណាមិនបាច់លាភិក្ខុផងគ្នា ២.អសមាទានចារោ ត្រាច់ទៅណាមិនបាច់យកត្រៃចីវរគ្រប់ប្រដាប់ អាចដាក់ទុកនៅកន្លែងបាន ៣.ភិក្ខុឆាន់គណភោជន និងបរមប្បរភោជនបាន ៤.យាវទត្ថចីវរំ ភិក្ខុទុកដាក់អតិរេកចីវរបានតាមប្រាថ្នា ៥.យោ ច តត្ថចីវរុប្បាទោស សោ នេសំ ភវិស្សតិ អានិសង្សលាភដែលកើតឡើងក្នុងទីនោះត្រូវបានតែភិក្ខុដែលគង់នៅក្នុងអាវាសនោះ ។

ភិក្ខុអ្នកក្រាលគ្រង និងអនុមោទនា ត្រូវបានអានិសង្ស៥ប្រការ ដូចបានបញ្ជាក់ខាងលើនេះ ។ ចំពោះទាយក ទាយិកាក៏បានអានិសង្សដ៏ក្រៃលែងច្រើនជាអនេកប្បការ ដូចជាស្លាប់ពីលោកនេះទៅ៧កើតសុគតិភព លុះចុតិពីសុគតិភពមកឋានមនុស្ស បានជាស្តេចចក្រពត្តិគ្រប់គ្រងទ្វីបទាំងបួន អស់បុណ្យពីស្តេចចក្រពត្តិ មកកើតស្តេចតូចៗ អស់ពីស្តេចតូចៗមកកើតជាសេដ្ឋីគហបតី អស់ពីគហបតីមកកើតកូនអ្នកមាន កូនអ្នកក្រមិនកើតទេ នេះជាអានិសង្ស

ដែលអ្នកធ្វើកឋិន ត្រូវបានអានិសង្សនេះឯងហៅថា នាមធម៌ ។ វត្ថុ ឬរបស់ដែលធ្វើឱ្យកើតជាកឋិនមានបីៈ ស្បង់មួយ ចីពរមួយ សង្ឃាដីមួយ ទាំងបីនេះហៅថា ត្រៃ របស់ក្រៅពីត្រៃមានៈ បាត្រ ឆត្រ កន្ទេល ខ្នើយ ព្រំ គ្រែ តុ ទូ កៅអី ហៅថា បរិក្ខាររបស់កឋិន។ ស្បង់ ចីពរ សង្ឃាដី យកតែស្បង់មួយធ្វើកឋិនក៏បាន។ ប៉ុន្តែពាក្យថា កឋិននេះធ្វើកម្រ បានត្រឹមត្រូវតាមវិន័យបញ្ញត្តិណាស់ បើផ្នែកឧបាសក ឧបាសិកា កាត់ស្បង់ចីពរត្រឹមត្រូវតាមវិន័យបញ្ញត្តិ ហើយ បដិគ្គាហកៈក្រាលគ្រងបានត្រឹមត្រូវតាមវិន័យបញ្ញត្តិ កឋិននេះឈ្មោះថា បានអានិសង្សទាំងអ្នកទទួល ទាំងអ្នកឱ្យ ដូចបានបញ្ជាក់ជូនខាងលើ។ ប៉ុន្តែបើទាយក ទាយិកា កាត់ស្បង់ចីពរបានត្រឹមត្រូវយកធ្វើកឋិន ប៉ុន្តែបដិគ្គាហកៈ ភិក្ខុអ្នកក្រាលគ្រងមិនបានត្រឹមត្រូវ កឋិននេះមិនបានកើតជាកឋិន ក្លាយជាបុណ្យបច្ច័យបួន អានិសង្សមិនបានដល់ ភិក្ខុអ្នកក្រាលគ្រងទេ បានតែទាយក ទាយិកាអ្នកឱ្យ។ បុណ្យទាំងអស់ក្នុងព្រះពុទ្ធសាសនា អានិសង្សដែលត្រូវបាន គឺបានតែទាយក ទាយិកា ឧបាសក ឧបាសិកា ជាអ្នកឱ្យទេ អ្នកទទួលមិនបានអានិសង្សទេ។ ដោយឡែកប្លែកតែ បុណ្យកឋិន ព្រោះបុណ្យកឋិនបានទាំងសងខាង គឺអ្នកឱ្យក៏បានអានិសង្ស អ្នកទទួលក៏បានអានិសង្ស។ ការធ្វើកឋិន មិនបានត្រឹមត្រូវតាមវិន័យបញ្ញត្តិជាវិបត្តិយ៉ាងធ្ងន់ចំពោះភិក្ខុសង្ឃអ្នកក្រាលគ្រង និងអ្នកអនុមោទនា។ ឯទាយក ទាយិកា ឧបាសក ឧបាសិកា អ្នកឱ្យមិនមានវិបត្តិអ្វីឡើយ គ្រាន់តែមិនបានអានិសង្សកឋិន ត្រឡប់ទៅជាបានអានិសង្សបច្ច័យបួនវិញ។ វិបត្តិភិក្ខុសង្ឃ គឺសម្គាល់ថា បានក្រាលគ្រង និងអនុមោទនាកឋិនរួចហើយ ១.ទុកសង្ឃាដីនៅ កន្លែងនិមន្តទៅកាន់ទីកន្លែងផ្សេងៗ ២.ទុកអតិរេកចីវរឱ្យលើសពី ១០ថ្ងៃ ៣.ឆាន់គណភោជន និងបរមប្បរភោជន ព្រមគ្នា។ និមន្តទៅណាមិនបានប្រាប់ភិក្ខុផងគ្នា អស់រយៈពេល ៥ខែសម្គាល់ថា អានិសង្សកឋិន ដែលត្រូវបាន។ ចុះបើធ្វើកឋិនមិនត្រូវតាមវិន័យបញ្ញត្តិ ហើយអ្នកក្រាលគ្រងកឋិនក៏មិនត្រឹមត្រូវជាវិបត្តិដល់ភិក្ខុ អស់រយៈពេល ៥ខែ ចាប់ពីថ្ងៃ ១រោច ខែអស្សុជ ដល់ថ្ងៃពេញបូណ៌មី ខែផល្គុន ចំពោះភិក្ខុសង្ឃដែលក្រាលគ្រងកឋិនមិនត្រឹមត្រូវ តាមវិន័យនោះ គឺភិក្ខុអ្នកក្រាលគ្រងមិនចេះ ឬមិនយល់នូវអានិសង្ស ៥ មិនយល់ មិនដឹងនូវមាតិកា ៨ បលិពោធ ២ ក៏មិនយល់ អនត្ថតាការ ២៤ ក៏មិនដឹង មិនយល់ អត្ថតាការ ១៧ ក៏មិនយល់ មិនដឹង។ ភិក្ខុអ្នកក្រាលគ្រងកឋិន បើ មិនយល់ មិនដឹងនូវលក្ខណៈ ៥ចំណុចនេះ ប្រសិនបើក្រាលគ្រងកឋិនៗនោះមិនកើតជាកឋិនទេ កឋិនក្លាយទៅជា បច្ច័យបួនពិតប្រាកដ។ លក្ខណៈ៥នេះ បើមិនបានចាំឱ្យបានយល់ខ្លះៗក្នុងចំណុចមួយៗ ហើយក្រាលគ្រងកឋិន កឋិន នោះមិនវិបត្តិទេ បានកើតជាកឋិនពេញលេញ។

ដូច្នេះហើយបានជា លោកអ្នកប្រាជ្ញទាំងឡាយបានប្រៀបធៀបការធ្វើកឋិនទៅនឹងឈើស្នឹង ឈើស្នឹងគឺជា ឈើដែលគេកាត់ដាច់ពាក់កណ្តាលដើម ហើយគេយកចំណែកខាងចុងទៅដោតវានឹងផែនដី ឈើនោះកម្រនឹងបាន

ដុះលូតលាស់ ។ យ៉ាងណាមិញ រីឯបុណ្យកឋិនក្រធ្វើឱ្យបានត្រឹមត្រូវតាមវិន័យបញ្ញត្តិក៏យ៉ាងនោះដែរ ។

ស្បង់ចីពរ ដែលព្រះសម្មាសម្ពុទ្ធទ្រង់អនុញ្ញាតឱ្យប្រើមានចីវរបួនបែប ៖ ១.ចីពរបញ្ចខ័ណ្ឌ ២.ចីពរសតខ័ណ្ឌ ៣.ចីពរនវខ័ណ្ឌ ៤.ចីពរឯកាទសខ័ណ្ឌ ។ ប៉ុន្តែនៅប្រទេសកម្ពុជា និងនៅសហរដ្ឋអាមេរិក គេឃើញប្រើចីពរញឹកញាប់ច្រើនជាងគេ គឺចីពរបញ្ចខ័ណ្ឌ ឯចីពរសតខ័ណ្ឌ ចីពរនវខ័ណ្ឌ និងចីពរឯកាទសខ័ណ្ឌ ពុំសូវឃើញប្រើទេ ។ ចំពោះចីពរបួនបែបនេះ ព្រះពុទ្ធជាម្ចាស់ទ្រង់អនុញ្ញាតឱ្យតែអ្នកបួសក្នុងលទ្ធិថេរវាទ (ហីនយាន) ទេ ។ សម័យខាងដើមមានចីពរមួយបែបទៀតហៅថា ចីពរខ្ចង់ប្រក់ ។ ចីពរខ្ចង់ប្រក់នេះ អ្នកបួសក្នុងលទ្ធិថេរវាទនៅប្រទេសកម្ពុជាសម័យខាងដើម មានឃើញប្រើច្រើន ប៉ុន្តែចីពរខ្ចង់ប្រក់នេះមិនមានក្នុងបិដកទេ ។ នៅប្រទេសអ្នកកាន់ពុទ្ធសាសនា លទ្ធិថេរវាទ (ហីនយាន) ទាំងអស់ក៏មិនឃើញប្រើចីពរខ្ចង់ប្រក់នេះដែរ ។ រីឯចីពរបញ្ចខ័ណ្ឌមានមហាមណ្ឌល ៥ អឌ្ឍមណ្ឌល ៥ (មហាមណ្ឌលហៅថា កន្លែងធំ អឌ្ឍមណ្ឌលគឺកន្លែងតូច) មហាមណ្ឌល ៥ អឌ្ឍមណ្ឌល៥ បូកបញ្ចូលគ្នាត្រូវជាមណ្ឌល ១០ ឬហៅកន្លែងធំ ៥ កន្លែងតូច ៥ បូកបញ្ចូលគ្នាត្រូវជាកន្លែង ១០ ។ ចីពរសតខ័ណ្ឌ កន្លែងធំ ៧ កន្លែងតូច ៧ សរុបជាកន្លែង ១៤ ។ ចីពរនវខ័ណ្ឌ មានកន្លែងធំ ៩ កន្លែងតូច ៩ សរុបចូលគ្នាត្រូវជាកន្លែង ១៨ ។ ចីពរឯកាទសខ័ណ្ឌមានកន្លែងធំ ១១ កន្លែងតូច ១១ សរុបចូលគ្នាត្រូវជាកន្លែង ២២ ។

ក្នុងបឋមពោធិកាល ព្រះអង្គទ្រង់អនុញ្ញាតក្នុងសាសនមណ្ឌលរបស់ព្រះអង្គឱ្យភិក្ខុទាំងឡាយប្រើប្រាស់បង្សុកូលចីវរ គឺភិក្ខុនិមន្តដើររកសំពត់បង្សុកូលទៅតាមព្រៃស្មសាន ឬតាមច្រកល្ហក ឬព្រៃខ្មោច ឬក្រណាត់សំពត់ ដែលគេចងរយាលចាប ឬសំពត់ដែលគេរុំសាកសព យកទៅបោះចោលក្នុងព្រៃឱ្យសត្វចចក ឬសត្វខ្លាស៊ី ពេលដែលឆ្កែចចកស៊ីអស់សាកសពនៅសល់ក្រណាត់ ដែលគេរុំសពប្រឡាក់ដោយខ្ទុះ ដោយឈាម ហើយជាប់ដោយក្លិនស្អុយ ភិក្ខុសង្ឃទៅបង្សុកូលទាញយកក្រណាត់នោះមកបោកទឹកឱ្យស្អាត ហើយយកមកធ្វើជាចីពរប្រើប្រាស់ ។ លុះដល់មជ្ឈិមពោធិកាល ទើបមានគហបតីចីវរ ដែលហៅថា គហបតីចីវរ គឺចីវរដែលគេកាត់ដេរស្រេច ហើយបានយកមកធ្វើកឋិន ។ ចីពរបែបនេះហៅថា គហបតីចីវរ ។

រៀបរៀងដោយ ៖ ព្រះចៅអធិការវត្តគិរីវង្សាបុប្ផារាម ទីក្រុងឡេវវើរ៉េត រដ្ឋម៉ាសាឈូសិត្តស៍ សហរដ្ឋអាមេរិក

គ្រូធម្មាចារ្យវិបស្សនាធុរៈ ព្រះភិក្ខុ តេជប្បញ្ញោ ផន ភាព ខែមិគសិរ ព.ស.២៥៥៤ ខែធ្នូ គ.ស.២០១០